ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

គណៈកម្មាធិការលទ្ធកម្ម

លេខ ៩៤៣ PC.អក

# សេចក្តីជូនដំណឹង

## ស្តីពី

## ការពន្យារពេលបើកឯកសារដេញថ្លៃ ដេញថ្លៃមានកម្រិត និងពិគ្រោះថ្លៃ

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ៖ ដោយយោងតាមស្ថានភាពនៃការចម្លងក្នុងសហគមន៍ក្នុងព្រឹត្តិការណ៍សហគមន៍ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ មិនទាន់ធូរស្រាល និងដើម្បីជៀសវាងការឆ្លងជំងឺកូវីដ-១៩ អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាសទាំងអស់ ដែលបានចូលរួមទិញឯកសារដេញថ្លៃ ដេញថ្លៃមានកម្រិត និងពិគ្រោះថ្លៃ ដែលគ្រោងនឹងបើកឯកសារ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ខាងមុខ ត្រូវពន្យារពេលបើកឯកសារ តាមកាលបរិច្ឆេទដូចខាងក្រោម ៖

I. គម្រោងដេញថ្លៃ ៖ ការផ្គត់ផ្គង់សាច់ក្រណាត់ឯកសណ្ឋាន ស្លាកឈ្មោះ និងស្លាកសញ្ញា ជូននិយោជិតកម្មករ នៃអគ្គិសនីកម្ពុជាសម្រាប់ឆ្នាំ២០២១ (ភ្នំពេញ និងអគ្គិសនីខេត្តចំនួន១៥) ត្រូវពន្យារពេលបើកឯកសារទៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០២១ វេលាម៉ោង ១៥ : ០៥ ។

II. គម្រោងដេញថ្លៃមានកម្រិត ៖ ការផ្គត់ផ្គង់ Concrete Pole ចំនួន ០១មុខ ជូននាយកដ្ឋានអាជីវកម្មចែកចាយ ត្រូវពន្យារពេលបើកឯកសារទៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០២១ វេលាម៉ោង ១៥ : ១០ ។

III. គម្រោងពិគ្រោះថ្លៃ ៖ ការងារបំពាក់ម៉ាស៊ីនត្រជាក់ ចំនួន ០២គ្រឿង នៅអនុស្ថានីយអគ្គិសនីប្រែកម្នេស ជូននាយកដ្ឋានបញ្ជូនអគ្គិសនី (លើកទី២) ត្រូវពន្យារពេលបើកឯកសារទៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០២១ វេលាម៉ោង ១៥ : ១៥ ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមបណ្តាក្រុមហ៊ុនផ្គត់ផ្គង់/សហគ្រាស ទាំងអស់ជ្រាបជាព័ត៌មាន ។

ថ្ងៃអង្គារ ១១រោច ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០២១

ជ. ប្រធានគណៈកម្មាធិការលទ្ធកម្ម

ហង់_នួច

**ចម្លងជូន៖**

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-នាយកដ្ឋានបញ្ជូនអគ្គិសនី

-នាយកដ្ឋានអាជីវកម្មចែកចាយ

-នាយកដ្ឋានរដ្ឋបាល

-ឯកសារកាលប្បវត្តិ